01077184

E345

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
31 / 03 / 2015
ម៉ោង (Time/Heure): 09:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥

**ផ្ញើជូន៖** **គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **ការដាក់ឯកសារថ្មីចូលទៅក្នុងសំណុំរឿង *តាមការផ្តួចផ្តើមគំនិតដោយខ្លួនឯង* (*sua sponte*)**

1. នៅលើឃ្លាំងផ្ទុកឯកសាររួម (SMD) មានព្រឹត្តិបត្រសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យមួយ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៧៨ ដែលមានចំណងជើងថា "អាងស្តុកទឹក "១ មករា" គឺជានិមិត្តសញ្ញានៃវីរភាពនៃប្រជាជនកម្ពុជាក្នុងការកសាងប្រទេស" (ឯកសារ 01076453-01076454)។ ឯកសារនេះពាក់ព័ន្ធនឹងការដ្ឋានទំនប់ ១ មករា ដែលត្រូវបានដាក់ទៅក្នុងឃ្លាំងផ្ទុកឯកសាររួម តាំងពីថ្ងៃ ទី ០៥ ខែ មិថុនា ឆ្នាំ ២០០៧ ហើយឯកសារនេះមានជាបីភាសាផ្លូវការរបស់ អ.វ.ត.ក។

2. លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ខ្សែវីដេអូមួយដែលថតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងផលិតឡើងដោយគណៈប្រតិភូអ្នកកាសែតយូហ្គោស្លាវី (*សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ ១៥-១៦)។ សម្រង់នៃឃ្លុតខ្សែវីដេអូដើម មាននៅក្នុងសំណុំរឿង នៅក្នុងឯកសារ E3/3091R (នៅត្រង់នាទី ៤៣:៣០ *និងបន្តបន្ទាប់ទៀត*) ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ (ឯកសារ E185/1.3)។ តាំងពីពេលនោះមក អង្គជំនុំជម្រះបានទទួលខ្សែវីដេអូដើម

ពេញលេញពីបណ្ណសារមជ្ឈមណ្ឌលបុប្ផាណា ដែលខ្សែវីដេអូនេះនិយាយជាភាសាសែប៊ី។ អង្គជំនុំជម្រះកំពុងស្នើសុំឲ្យមានការបកប្រែជាភាសាអង់គ្លេស និងធ្វើប្រតិចារឹកនៃឯកសារដើម។

3. អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះបំពេញនូវបទដ្ឋាន*បញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលត្រូវបានតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងអាចនាំទៅរកការបញ្ជាក់ការពិត។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចដាក់ឯកសារទាំងនេះចូលទៅក្នុងសំណុំរឿងអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ប្រតិចារឹកនៃខ្សែវីដេអូនេះ នឹងត្រូវដាក់ចូលទៅក្នុងសំណុំរឿងនៅពេលការធ្វើប្រតិចារឹកបានបញ្ចប់។